ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ៖ ២៥៥/ម.ជ.ម./២៤

# សេចក្តីណែនាំ
# ស្តីពី
# ការប្រើប្រាស់យន្តការដោះស្រាយវិវាទ តាមរយៈមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb) របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** (ម.ជ.ម.) សង្កេតឃើញថា យន្តការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb) ត្រូវបានប្រើប្រាស់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ជាពិសេសវិវាទពាណិជ្ជកម្មឆ្លងព្រំដែន។

យន្តការមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb) គឺជាដំណើរការនៃការដោះស្រាយ វិវាទដែលគូភាគីបញ្ជូនវិវាទរបស់ខ្លួនទៅដោះស្រាយដោយមជ្ឈត្តការ មុននឹងព្យាយាមដោះស្រាយតាមរយៈសន្ធានកម្ម។ ប្រសិនបើគូភាគីអាចដោះស្រាយវិវាទរបស់ខ្លួនតាមរយៈសន្ធានកម្ម កិច្ចព្រមព្រៀងសះជារបស់ពួកគេអាចកត់ត្រាជាមជ្ឈត្តវិនិច្ឆ័យផ្អែកតាមការព្រមព្រៀង។ មជ្ឈត្តវិនិច្ឆ័យផ្អែកតាមការព្រមព្រៀងជាទូទៅគឺជាមជ្ឈត្តវិនិច្ឆ័យដែលអាចនឹងទទួលស្គាល់ និងដាក់ឱ្យអនុវត្តជាង ១៧០ ប្រទេស ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលធ្វើនៅទីក្រុងញូវយ៉ក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៨ (អនុសញ្ញាទីក្រុងញ៉ូវយ៉ក)។ ប្រសិនបើគូភាគីមិនអាចដោះស្រាយវិវាទរបស់ពួកគេតាមរយៈសន្ធានកម្ម គូភាគីអាចបន្តធ្វើនីតិវិធីមជ្ឈត្តការតទៅទៀត។

ក្នុងករណីនេះ ប្រសិនបើគូភាគីមានបំណងដោះស្រាយវិវាទ ដោយប្រើប្រាស់យន្តការ មជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb) ដែលចាត់ចែងដោយ ម.ជ.ម. គូភាគីអាចពិចារណាបញ្ចូលខចែងស្តីពីមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb Clause) នៅក្នុងកិច្ចសន្យារបស់ខ្លួនដូចខាងក្រោម៖

**គំរូខចែងស្តីពីមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb Model Clause)**

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ ចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.) ដែលមានសុពលភាពអនុវត្តនៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

គូភាគីព្រមព្រៀងបន្ថែមថា បន្ទាប់ពីចាប់ផ្តើមដំណើរការមជ្ឈត្តការ គូភាគីនឹងព្យាយាមដោះស្រាយវិវាទដោយសន្តិវិធីតាមរយៈសន្ធានកម្ម ដែលចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីសន្ធានកម្មរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (វិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.) ដែលមានសុពលភាព អនុវត្តនៅពេលចាប់ផ្តើមដំណើរការសន្ធានកម្ម ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករ ចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

គូភាគីអាចពិចារណាអំពីប្រការបន្ថែមដូចខាងក្រោម៖

**១. ភាសាសម្រាប់សន្ធានកម្ម**

ភាសាសម្រាប់ដំណើរការសន្ធានកម្មគឺ [ជ្រើសរើសភាសា]។

**២. ទីកន្លែងសន្ធានកម្ម**

ទីកន្លែងសម្រាប់សន្ធានកម្មគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។***

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________****។

---

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគី វិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស ]" )។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើសនៃទីកន្លែងធ្វើសន្ធានកម្មរបស់ខ្លួន។ ប្រសិនបើគូភាគី វិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើសន្ធានកម្មផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស"])។

**** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។

សម្រាប់ព័ត៌មានបន្ថែម អំពីយន្តការដោះស្រាយវិវាទ តាមរយៈមជ្ឈត្តការ-សន្ធានកម្ម-មជ្ឈត្តការ (Arb-Med-Arb) ដែលចាត់ចែងដោយ ម.ជ.ម. សូមទំនាក់ទំនងមកអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. តាមរយៈលេខទូរសព្ទ៖ (+៨៥៥) ៩៦ ៨៨៨ ៥៣៣៣ ឬតាមរយៈអ៊ីម៉ែល៖ info@ncac.org.kh នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ២ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**
**ប្រធាន**

NATIONAL COMMERCIAL ARBITRATION CENTRE

មជ្ឈត្តការ សាន គិរី